អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា
Kampuchea Action to Promote Education (KAPE)

# សេចក្តីណែនាំ និងឯកសារភ្ជាប់បញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ

## ឯកសារភ្ជាប់បញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ

អ្នកដេញថ្លៃទាំងអស់ ត្រូវភ្ជាប់ជាមួយនូវឯកសារភស្តុតាង បង្ហាញពីលក្ខណៈសម្បត្តិរបស់ខ្លួនមានដូចខាងក្រោម៖

- **វិញ្ញាបនបត្រចុះឈ្មោះក្រុមហ៊ុន ឬអាជីវកម្ម ក្នុងបញ្ជីក្រសួងពាណិជ្ជកម្ម (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់**
- **ប័ណ្ណប៉ាតង់ប្រចាំឆ្នាំ២០២៤ (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់**
- **វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់**
- **ឯកសារភស្តុតាងសម្រាប់បញ្ជាក់ពីសមត្ថភាពបច្ចេកទេស និងបទពិសោធន៍ក្នុងការផ្គត់ផ្គង់របស់ខ្លួន ០១ ច្បាប់**
- **អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់**

ក្រុមហ៊ុន សហគ្រាស សាជីវកម្ម ឬអាជីវករ និងអ្នកទទួលការផ្គត់ផ្គង់សម្ភារព័ត៌មានវិទ្យា ទាំងអស់ដែលមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ក្នុងករណីពិនិត្យឃើញថា៖ ក្រុមហ៊ុន សហគ្រាស សាជីវកម្ម ឬអាជីវករ និងអ្នកទទួលការផ្គត់ផ្គង់ដែលបានចូលរួមធ្វើការដេញថ្លៃជាក្រុមហ៊ុនមានសម្ព័ន្ធភាពតែមួយ ឬប្រភពតែមួយ នឹងត្រូវបដិសេធដោយស្វ័យប្រវត្តិ។

**<u>បញ្ជាក់៖</u>**

1. ការទទួលឯកសារភ្ជាប់បញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃចាប់ពីថ្ងៃទី០២ ដល់ ថ្ងៃទី០៩ ខែសីហា ឆ្នាំ ២០២៤ វេលាម៉ោង ៨:៣០នាទី ព្រឹក តាមរយៈសារអេឡិចត្រូនិច (អ៊ីមែលជូនភ្ជាប់ខាងក្រោម)។
2. ការតម្រង់ទិសអំពីនិតិវិធីនៃការដេញថ្លៃធ្វើទៅតាមរយៈអនឡាញ (Zoom Meet) នឹងប្រព្រឹត្តិទៅនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៤ វេលាម៉ោង៩:៣០នាទី ព្រឹក(ទីកន្លែង៖ ការិយាល័យកណ្តាលអង្គការ ខេប)។
3. ការទទួលកញ្ចប់ឯកសារ និងពាក្យស្នើសុំចូលរួមដេញថ្លៃ **ចាប់ពីថ្ងៃទី០៩** រហូតដល់ **ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០២៤** វេលាម៉ោង ៥:០០ល្ងាច ជាកំហិត។
4. អ្នកចូលរួមដេញថ្លៃទាំងអស់តម្រូវឱ្យដាក់តំកល់ប្រាក់កក់ចំនួន៥%នៃតម្លៃដេញថ្លៃសរុប ក្នុងការផ្គត់ផ្គង់សម្ភារព័ត៌មានវិទ្យា ដើម្បីទទួលបានសិទ្ធិចូលរួមបើកកញ្ចប់ដេញថ្លៃ។ ក្រោយការបើកកញ្ចប់ដេញថ្លៃ ប្រសិនបើក្រុមហ៊ុន សហគ្រាស សាជីវកម្ម/អាជីវករ និងអ្នកទទួលផ្គត់ផ្គង់ណាដែលមិនបានឈ្នះជាប់ក្នុងការដេញថ្លៃនោះទេ អង្គការនឹងបង្វែរទឹកប្រាក់កក់គ្រប់ចំនួនទាំងអស់ត្រឡប់ជូនទៅឱ្យក្រុមហ៊ុនវិញ ក្នុងរយៈពេលយឺតបំផុតមួយសប្តាហ៍ក្រោយពេលដេញថ្លៃរួច។
5. ការប្រជុំបើកកញ្ចប់ដេញថ្លៃត្រូវរៀបចំធ្វើឡើងនៅការិយាល័យកណ្តាលអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ដែលមានទីតាំងស្ថិតនៅក្នុងបរិវេណសាលាគរុកោសល្យ និងវិក្រឹតការ ខេត្តកំពង់ចាម /ក្រុងកំពង់ចាម។
6. រាល់ឯកសារសម្រង់តម្លៃ និងពាក្យស្នើសុំចូលរួមការដេញថ្លៃ ត្រូវវេចខ្ចប់ចូលក្នុងស្រោមរួចបិទជិត (ផ្ដុំបេ) ដោយមានចុះហត្ថលេខា និងបោះត្រារបស់ក្រុមហ៊ុន ម្ចាស់សហគ្រាសសាជីវកម្ម/អាជីវកម្ម នៅលើស្រោមសំបុត្រ រួចបញ្ជូនមកការិយាល័យកណ្តាលអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ហៅកាត់ថា ខេប) តាមអាសយដ្ឋានខាងលើ។

រាល់ឯកសារសម្រង់តម្លៃដេញថ្លៃទាំងអស់ ត្រូវរាប់បញ្ចូលនូវប្រាក់ពន្ធអាករលើតម្លៃបន្ថែម ១០% និងការបញ្ចុះតម្លៃរួចជាស្រេចផងដែរទៅតាមមុខសម្ភារព័ត៌មានវិទ្យានីមួយៗ ហើយមិនអនុញ្ញាតឱ្យដាក់ផ្ញើមកតាមរយៈសារអេឡិចត្រូនិច (អ៊ីមែល)ជាដាច់ខាត។

7. រាល់ឯកសារសម្រង់តម្លៃនិងពាក្យស្នើសុំចូលរួមការដេញថ្លៃទាំងអស់ ដែលមិនបានដាក់ជូនមកការិយាល័យកណ្ដាលរបស់អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ទាន់ពេលវេលាទេ និងមិនបានដាក់ដំកល់ប្រាក់កក់ ៥% ទៅតាមការណែនាំដូចមានចែងខាងលើ ត្រូវបានចាត់ទុកជាអាសាបង់ និងទុកជានិរាករណ៍។
8. អ្នកចូលរួមដេញថ្លៃទាំងអស់ ដែលមានសិទ្ធិចូលរួមដេញថ្លៃ ត្រូវបានអង្គការផ្ញើលិខិតអញ្ជើញជាផ្លូវការ ដើម្បីមកចូលរួមប្រជុំដោយចំហក្នុងការបើកកញ្ចប់ដេញថ្លៃឱ្យទាន់ពេលវេលា។ ប្រសិនបើអ្នកដេញថ្លៃណាដែលមានសិទ្ធិចូលរួមហើយ តែមិនបានមកចូលរួមប្រជុំបើកសម្រង់តម្លៃទាន់ពេលវេលាបានកំណត់ អវត្តមាន ឬក៏មកយឺតរយៈពេល ១៥ នាទី ឯកសារដាក់ដេញថ្លៃនោះនឹងមិនអនុញ្ញាតឱ្យដាក់បញ្ចូលក្នុងការបើកឡើយ។
9. ចំពោះអ្នកចូលរួមប្រជុំការបើកបញ្ចប់ឯកសារដេញថ្លៃទាំងអស់ដែលមកក្នុងនាមជាអ្នកតំណាងក្រុមហ៊ុនសហគ្រាស សាជីវកម្ម/អាជីវករ និងអ្នកទទួលផ្គត់ផ្គង់ ត្រូវតែមានកាន់លិខិតផ្ទេរសិទ្ធិ ដែលមានចុះហត្ថលេខាត្រឹមត្រូវពីប្រធានក្រុមហ៊ុន ម្ចាស់សហគ្រាស/អាជីវកម្ម។
10. យើងខ្ញុំសូមរក្សាសិទ្ធិក្នុងការផ្លាស់ប្ដូរនៃការបើកកញ្ចប់ឯកសារដេញថ្លៃ ប្រសិនបើមានការចាំបាច់ ហើយយើងខ្ញុំនិងជូនដំណឹងទៅក្រុមហ៊ុន ឬសហគ្រាស សាជីវកម្ម/អាជីវករ និងអ្នកទទួលការផ្គត់ផ្គង់ដែលបានផ្ញើឯកសារដេញថ្លៃមកជាមុន)។
11. រាល់ឯកសារដេញថ្លៃដែលបានដាក់មកហើយ គណៈកម្មការយើងខ្ញុំមិនប្រគល់ជូនត្រឡប់ទៅវិញទេ។